**ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៦)**

| **ឈ្មោះសេវា** | **ការផ្តល់សេវាពិនិត្យសំណើសុំបង្កើត រោងសន្និធិលក់ចែកចាយផល អនុផល ព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច** |
|---|---|
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>-ខណ្ឌរដ្ឋបាលព្រៃឈើ<br>-ទីស្នាក់ការខណ្ឌរដ្ឋបាលព្រៃឈើ តាមបណ្តាខេត្ត ក្រុង និងរាជធានី |
| **គោលបំណងនៃសេវា** | ដើម្បីសម្រួលដល់ការធ្វើអាជីវកម្មកែច្នៃ ផល អនុផលព្រៃឈើ |
| **មូលដ្ឋានគតិយុត្ត** | -ច្បាប់ស្តីពីព្រៃឈើ មាត្រា ២៥-២៦-៧១ និង ១០៧<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨<br>-ប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវច្បាប់អនុញ្ញាតមានការប្រែប្រួលទៅតាមករណីនីមួយៗ អាស្រ័យទៅតាមលទ្ធផលនៃការវាយតម្លៃលើភាពស្រប ឬ មិនស្របច្បាប់នៃប្រភពផ្គត់ផ្គង់ ផល អនុផលព្រៃឈើ ទីតាំង និងលក្ខណៈគ្រប់គ្រាន់នៃសំណុំឯកសារដែលបានស្នើសុំ។ ក្នុងរយៈពេល៧ថ្ងៃនៃថ្ងៃការងារ(ខណ្ឌរដ្ឋបាលព្រៃឈើ)នឹងជូនដំណឹងទៅរូបវន្តបុគ្គល ឬនីតិបុគ្គលអំពីភាពស្រប ឬមិនស្រប និងលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃសំណុំឯកសារ ដែលបានស្នើសុំ។<br>-តំលៃ (នឹងកំណត់នៅពេលក្រោយ)។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | -ប្រវត្តិរូបសង្ខេប<br>-ព័ត៌មានពិស្តាររបស់សង្កាត់រដ្ឋបាលព្រៃឈើ<br>-ឯកសារបញ្ជាក់ប្រភពផ្គត់ផ្គង់វត្ថុធាតុដើម(ផល អនុផលព្រៃឈើ) ឬកិច្ចសន្យា<br>-ប្លង់កម្មសិទ្ធិនៃទីតាំងស្នើសុំ ឬកិច្ចសន្យាជួលដី ឬទីតាំង<br>-កិច្ចសន្យារបស់ម្ចាស់រោងសន្និធិលក់ចែកចាយផល អនុផល ព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ចំពោះសមត្ថកិច្ច រដ្ឋបាលព្រៃឈើមូលដ្ឋាន<br>-លិខិតសុវិធាន និងអសុវិធាន(សេចក្តីយល់ព្រមរបស់ប្រជាពលរដ្ឋដែលរស់នៅ ជុំវិញទីតាំងរោងឧស្សាហកម្ម រោងចក្រ ឬសិប្បកម្ម ដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី<br>-បញ្ជីរាយនាមគ្រឿងចក្រ-សំភារៈឧបករណ៍កែច្នៃផល អនុផលព្រៃឈើ<br>-គូសប្លង់ទីតាំង និង ប្លង់បច្ចេកទេស សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយមានបញ្ជាក់ និងយល់ព្រមពីសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់<br>-កំណត់ហេតុ និងរបាយការណ៍វាយតម្លៃលក្ខណៈបច្ចេកទេស និងទីតាំងស្នើសុំ។ |

| | |
|---|---|
| **យោបល់** | ដំណើរការនៃការស្នើសុំ និងបំពេញបែបបទសុំច្បាប់អនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ចែកចេញជា ៣ ដំណាក់កាល (១) ការដាក់ពាក្យស្នើសុំ (២) ការពិនិត្យផ្តល់មតិរបស់ខណ្ឌរដ្ឋបាលព្រៃឈើ (៣) ការសំរេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ |

៙៙៙❈៚៚៚